# ប្រកាស
## ស្តីពី
## នីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនប្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែម មុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមាន

ថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ២២០ ប្រក.កសក.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត
- បានឃើញប្រកាសលេខ០៩០ ប្រក.កសក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានឃើញប្រកាសលេខ១៨៦ ប្រក.កសក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានីខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានីខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីសម្រាប់បង្កើតនិងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីសហគមន៍កសិកម្ម។

### ប្រការ ២.-

ប្រកាសនេះមានគោលដៅផ្តល់គោលការណ៍ណែនាំស្តីពីនីតិវិធីបង្កើតនិងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដល់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មទាំងអស់ដើម្បីរួមគ្នាបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដែលជារចនាសម្ព័ន្ធចាត់តាំងកំពូលស្របច្បាប់របស់សហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## នីតិវិធីនៃការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

### ផ្នែកទី១
### លក្ខខណ្ឌនៃការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

**ប្រការ ៤.-**

សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជាសមាជិកស្វ័យប្រវត្តិរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបង្កើតឡើងតាមរយៈមហាសន្និបាតតំណាងរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម ក្រោមការសម្របសម្រួលពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីសហគមន៍កសិកម្ម។

**ប្រការ ៥.-**

ដើម្បីចូលរួមបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មត្រូវមានលក្ខណៈសម្បត្តិ និងទទួលខុសត្រូវដូចខាងក្រោម៖

១-ត្រូវមាននីត្យានុកូលភាពតាមរយៈការចុះបញ្ជីសហគមន៍កសិកម្មឬការចុះបញ្ជីសហភាពសហគមន៍កសិកម្មស្របតាមច្បាប់ស្តីពីសហគមន៍កសិកម្មជាធរមាន។

២-ត្រូវដាក់ពាក្យស្នើសុំចូលជាសមាជិកសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

៣-ត្រូវជ្រើសតាំងសមាជិកតំណាងរបស់ខ្លួនដើម្បីចូលរួមបោះឆ្នោតជ្រើសរើសប្រតិភូតំណាងចូលរួមមហាសន្និបាតកំណើតដំបូង នៅក្នុងដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

៤-ត្រូវចូលរួមគាំទ្រដំណើរការអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នៅក្នុងមហាសន្និបាតកំណើតដំបូង។

៥-ត្រូវបំពេញរាល់ភារកិច្ចនៅក្នុងដំណើរការបង្កើតរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីសហគមន៍កសិកម្មជាធរមាន។

**ប្រការ ៦.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបំពេញមុខងារជាអង្គភាពសម្របសម្រួលនៅក្នុងដំណើរការរៀបចំនិងបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

នៅក្នុងរយៈពេលមិនលើសពី១២(ដប់ពីរ)ខែ នៅមុនពេលចាប់ផ្តើមមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវផ្តល់សេចក្តីជូនដំណឹងដល់គ្រប់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មតាមរាជធានី ខេត្តនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា អំពីដំណើរការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

**ប្រការ ៧.-**

សេចក្តីជូនដំណឹងត្រូវផ្សព្វផ្សាយចំពោះសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មដូចខាងក្រោម៖

- ភាពចាំបាច់ និងសារៈសំខាន់នៃការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- តួនាទីនិងភារកិច្ចរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងផលប្រយោជន៍ដែលសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មទទួលបាន
- គោលការណ៍ណែនាំសម្រាប់ការជ្រើសរើសប្រតិភូតំណាងរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មសម្រាប់ការចូលរួមមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សេចក្តីណែនាំផ្សេងទៀតក្នុងក្របខ័ណ្ឌនៃដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវកំណត់កម្មវិធីការងារនិងគោលការណ៍ណែនាំចំពោះសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម សម្រាប់ការរៀបចំនិងអនុវត្តន៍ឆ្ពោះទៅកមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

**ប្រការ ៨.-**

ក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញដើម្បីផ្សព្វផ្សាយអំពីការចូលជាសមាជិកសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានិងត្រូវឆ្លុះបញ្ចាំងជូនសមាជិកសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មរបស់ខ្លួនដូចខាងក្រោម៖

- បង្ហាញអំពីសារៈសំខាន់និងភាពចាំបាច់របស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម ចំពោះការចូលរួមបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ជាអង្គការកំពូលតំណាងរបស់ខ្លួន
- បង្ហាញអំពីបេសកកម្ម តួនាទី និងភារកិច្ចរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពនិងការគាំទ្រចំពោះសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម ព្រមទាំងផលប្រយោជន៍ដែលទទួលបានពីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- បង្ហាញអំពីគោលការណ៍នៃការបោះឆ្នោតជ្រើសរើសបេក្ខភាពប្រតិភូតំណាងដើម្បីចូលរួមមហាសន្និបាតកំណើតដំបូង ការបោះឆ្នោតជ្រើសរើសបេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវចូលរួមបង្កើត។
- ធ្វើការបោះឆ្នោតជ្រើសរើសសមាជិកតំណាងសហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្មសាមី សម្រាប់ការចូលរួមបោះឆ្នោតជ្រើសរើសប្រតិភូតំណាង បេក្ខភាពក្រុមប្រឹក្សា

ភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវចូលរួមបង្កើត។

**ប្រការ ៩.-**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានភារកិច្ចសម្របសម្រួលក្នុងការងារជ្រើសតាំងតំណាងសហគមន៍កសិកម្មក្រោមដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីចូលរួមបោះឆ្នោតជ្រើសរើសប្រតិភូតំណាងសម្រាប់ចូលរួមក្នុងមហាសន្និបាតកំណើតដំបូងសម្រាប់ធ្វើជាបេក្ខជនក្រុមប្រឹក្សាភិបាល និងបេក្ខជនគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវចូលរួមបង្កើត។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តត្រូវចាត់ចែងដំណើរការបោះឆ្នោតជ្រើសរើសបេក្ខភាពប្រតិភូតំណាង បេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានៅក្នុងក្របខណ្ឌរាជធានី ខេត្តសាមី។

**ប្រការ ១០.-**

ចំនួនជាក់លាក់នៃប្រតិភូតំណាងរបស់សហគមន៍កសិកម្ម និងចំនួនជាក់លាក់នៃបេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យ ក្នុងក្របខណ្ឌរាជធានី ខេត្តនីមួយៗ ត្រូវសមាមាត្រទៅតាមចំនួនសហគមន៍កសិកម្មដែលបានចុះបញ្ជីរួច និងត្រូវកំណត់ដូចខាងក្រោម៖

១-រាជធានី ខេត្តដែលមានសហគមន៍កសិកម្មចាប់ពីចំនួន ១(មួយ) ដល់ ១០(ដប់) ត្រូវមានប្រតិភូតំណាងចំនួន ២(ពីរ)រូប បេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាលឬបេក្ខជនសម្រាប់គណៈកម្មាធិការត្រួតពិនិត្យចំនួន ១(មួយ)រូប។

២-រាជធានី ខេត្តដែលមានសហគមន៍កសិកម្មចាប់ពីចំនួន ១១(ដប់មួយ) ដល់ ៣០(សាមសិប) ត្រូវមានប្រតិភូតំណាងចំនួន ៤(បួន)រូប បេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាលឬបេក្ខជនសម្រាប់គណៈកម្មាធិការត្រួតពិនិត្យ ចំនួន ១(មួយ)រូប។

៣- រាជធានី ខេត្តដែលមានសហគមន៍កសិកម្មចាប់ពីចំនួន ៣១(សាមមួយ) ឡើងទៅត្រូវមានប្រតិភូតំណាងចំនួន ៦(ប្រាំមួយ)រូប បេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាលឬបេក្ខជនសម្រាប់គណៈកម្មាធិការត្រួតពិនិត្យចំនួន ២(ពីរ)រូប។

**ប្រការ ១១.-**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានភារកិច្ចធ្វើរបាយការណ៍បូកសរុបលទ្ធផលដំណើរការជ្រើសរើសប្រតិភូតំណាងសហគមន៍កសិកម្ម បេក្ខភាពសម្រាប់ក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យក្រោមដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់ការចូលរួមក្នុងមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងត្រូវបញ្ជូនមកនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មតាមកម្មវិធីកំណត់។

**ប្រការ ១២.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានភារកិច្ចសម្របសម្រួលក្នុងការងារជ្រើសតាំងតំណាងសហភាពសហគមន៍កសិកម្ម ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសប្រតិភូតំណាងសម្រាប់ចូលរួមក្នុង

មហាសន្និបាតកំណើតដំបូង សម្រាប់ធ្វើជាបេក្ខជនក្រុមប្រឹក្សាភិបាល និងបេក្ខជនគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវចូលរួមបង្កើត។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវចាត់ចែងដំណើរការបោះឆ្នោតជ្រើសរើសបេក្ខភាពប្រតិភូតំណាង បេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

## ប្រការ ១៣.-

ចំនួនជាក់លាក់នៃប្រតិភូតំណាងរបស់សហភាពសហគមន៍កសិកម្ម និងចំនួនជាក់លាក់នៃបេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យ សម្រាប់ចូលរួមមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវកំណត់ដូចខាងក្រោម៖

១-សហភាពសហគមន៍កសិកម្មដែលមានដើមទុនសរុបតិចជាង ៥០,០០០,០០០ រៀល (ហាសិបលានរៀល) មានប្រតិភូតំណាង ចំនួន ២(ពីរ)រូប បេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាល ឬបេក្ខជនសម្រាប់គណៈកម្មាធិការត្រួតពិនិត្យចំនួន ១(មួយ)រូប។

២-សហភាពសហគមន៍កសិកម្មដែលមានដើមទុនសរុបចាប់ពី ៥០,០០០,០០០ ដល់ ១០០,០០០,០០០ រៀល (ហាសិបលានដល់មួយរយលានរៀល) មានប្រតិភូតំណាងចំនួន៤(បួន) រូប និងបេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាល ឬបេក្ខជនសម្រាប់គណៈកម្មាធិការត្រួតពិនិត្យចំនួន១(មួយ)រូប។

៣-សហភាពសហគមន៍កសិកម្មដែលមានដើមទុនសរុបច្រើនជាង ១០០,០០០,០០០ រៀល (មួយរយលានរៀល) មានប្រតិភូតំណាង ចំនួន៦(ប្រាំមួយ) រូប និងបេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាល ឬបេក្ខជនសម្រាប់គណៈកម្មាធិការត្រួតពិនិត្យចំនួន០២(ពីរ)រូប។

## ប្រការ ១៤.-

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានភារកិច្ចធ្វើសំយោគលទ្ធផលទូទាំងប្រទេស និងរៀបចំបញ្ជីឈ្មោះប្រតិភូតំណាង បេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មសម្រាប់ការចូលរួមក្នុងមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

## ប្រការ ១៥.-

លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើជាបេក្ខភាពប្រតិភូតំណាង បេក្ខភាពក្រុមប្រឹក្សាភិបាល ឬបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យសម្រាប់ការចូលរួមមហាសន្និបាតកំណើតដំបូងនៅក្នុងដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានកំណត់ដូចខាងក្រោម៖

១.លក្ខណៈសម្បត្តិសម្រាប់បេក្ខភាពប្រតិភូតំណាងចូលរួមមហាសន្និបាតកំណើតដំបូងមានដូចខាងក្រោម៖

- មានកម្រិតវប្បធម៌សមស្រប
- មានសីលធម៌រស់នៅល្អ
- មានការយល់ដឹងច្រើនពីតួនាទីនិងសារៈសំខាន់របស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

២. លក្ខណៈសម្បត្តិសម្រាប់បេក្ខជនឈរឈ្មោះបេក្ខភាពក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការត្រួតពិនិត្យមានដូចខាងក្រោម៖

- មានអាយុមិនលើសពី៦៥(ហុកសិបប្រាំ) ឆ្នាំ
- មានកម្រិតវប្បធម៌ ឬជំនាញវិជ្ជាជីវៈសមស្រប
- មានចំណេះដឹងនិងបទពិសោធន៍សមស្របលើការងារដឹកនាំនិងគ្រប់គ្រងសហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្ម
- សមាជិកក្រុមប្រឹក្សាភិបាលមិនអាចជាប្តីប្រពន្ធ ឪពុកម្តាយបង្កើត ឪពុកម្តាយក្មេក កូនបង្កើត ឬបងប្អូនបង្កើតរបស់សមាជិកណាមួយនៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការត្រួតពិនិត្យបានឡើយ
- សមាជិកក្រុមប្រឹក្សាភិបាលមិនអាចបំពេញតួនាទីព្រមគ្នា ជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យ ឬជាសវនករ ឬជាគណនេយ្យកររបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាឡើយ
- បេក្ខនារីត្រូវបានលើកទឹកចិត្តនិងផ្តល់អាទិភាព
- មិនធ្លាប់ទទួលទោសព្រហ្មទណ្ឌណាមួយឡើយ
- លក្ខខណ្ឌផ្សេងទៀតតាមការចាំបាច់ដែលត្រូវសម្រេចដោយមហាសន្និបាត។

## ផ្នែកទី២
## ការបង្កើតគណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

### ប្រការ ១៦.-

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវសម្របសម្រួលរៀបចំបង្កើត"គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា"ដែលនឹងត្រូវបំពេញភារកិច្ចក្នុងដំណើរការបង្កើតនិងការចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិស្នើសុំតំណាងរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងតំណាងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមបង្កើតជាគណៈកម្មការរៀបចំតាមការចាំបាច់។

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាបំពេញតួនាទីជាគណៈកម្មការបំពេញកិច្ច ដែលមានសមាសភាពចាប់ពី៧(ប្រាំពីរ)នាក់ឡើងទៅ និងបំពេញភារកិច្ចរបស់ខ្លួនចាប់ពីដំណាក់កាលផ្តើមការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ហើយនឹងត្រូវរំលាយទៅវិញដោយស្វ័យប្រវត្តិ នៅពេលដែលសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានចុះបញ្ជីជាផ្លូវការ។

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៧.-**

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានភារកិច្ចសម្របសម្រួលគ្រាដំបូងនៅក្នុងដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដូចខាងក្រោម៖

១- រៀបចំឯកសារចាំបាច់សម្រាប់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវបង្កើតដើម្បីដាក់ឆ្លងមហាសន្និបាតកំណើតដំបូង។

២- កោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

៣- រៀបចំនិងដាក់ពាក្យស្នើសុំការយល់ព្រមនិងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។

**ប្រការ ១៨.-**

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវសិក្សានិងរៀបចំឯកសារសម្រាប់ដាក់ឆ្លងមហាសន្និបាតកំណើតដំបូង នៅក្នុងដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដូចខាងក្រោម៖

១- រៀបចំបញ្ជីប្រតិភូតំណាងសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម ត្រូវចូលរួមមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

២- រៀបចំបញ្ជីសមាសភាពបេក្ខភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា សម្រាប់ដាក់ឆ្លងមហាសន្និបាតកំណើតដំបូង។

៣- រៀបចំសេចក្តីព្រាងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

៤- រៀបចំសេចក្តីព្រាងឯកសារស្តីពីបេសកកម្ម តួនាទី ភារកិច្ចនិងផែនការសកម្មភាពរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវបង្កើតក្នុងក្របខណ្ឌនៃការគាំទ្រ និងការកសាងសមត្ថភាពរបស់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥- រៀបចំឯកសារផ្សេងទៀតតាមការចាំបាច់។

## ផ្នែកទី៣
## ការរៀបចំមហាសន្និបាតកំណើតដំបូង

**ប្រការ ១៩.-**

មហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវប្រព្រឹត្តទៅក្រោមរូបភាពមហាសន្និបាតតំណាង ដែលមានការចូលរួមរបស់ប្រតិភូតំណាងសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មដែលបានបោះឆ្នោតជ្រើសរើសសម្រាប់ការចូលរួមមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសនេះ។

មហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា អាចប្រព្រឹត្តទៅបានលុះត្រាវត្តមាននៃប្រតិភូតំណាងចូលរួមមានចំនួន២/៣( ពីរភាគបី )នៃចំនួនប្រតិភូតំណាងសរុបដែលត្រូវចូលរួមមហាសន្និបាតកំណើតដំបូង។

**ប្រការ ២០.-**

ប្រតិភូតំណាង បេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មដែលត្រូវចូលរួមមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានសិទ្ធិបញ្ចេញមតិយោបល់នៅក្នុងមហាសន្និបាត និងមានសិទ្ធិបោះឆ្នោតទាំងអស់គ្នា។

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គការសង្គម និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បីចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ប៉ុន្តែអ្នកសង្កេតការណ៍ពុំមានសិទ្ធិបោះឆ្នោតឡើយ។

**ប្រការ ២១.-**

នៅក្នុងមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ប្រកាសអំពីសមាសភាព តួនាទីនិងភារកិច្ចរបស់គណៈកម្មការរៀបចំនៅក្នុងដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ប្រកាសអំពីគោលបំណងនៃការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ប្រកាសអំពីវត្តមាននៃប្រតិភូតំណាងរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មដែលមានចំនួនជាក់ស្តែងនៅក្នុងមហាសន្និបាត
- ប្រកាសអំពីបណ្តាឯកសារដែលបានរៀបចំសម្រាប់ការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដូចបានចែងនៅក្នុងប្រការ១៨ខាងលើ
- ដំណើរការបោះឆ្នោត ដើម្បីអនុម័តយល់ព្រមលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង សមាសភាពក្រុមប្រឹក្សាភិបាល គណៈកម្មាធិការត្រួតពិនិត្យនិងប្រាក់សមាជិកភាពរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ព្រមទាំងអនុម័តលើការងារពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍មហាសន្និបាតកំណើតដំបូង ដោយភ្ជាប់ជាមួយនូវបញ្ជីវត្តមាន រួមជាមួយហត្ថលេខាឬស្នាមមេដៃរបស់សមាជិកដែលបានចូលរួមមហាសន្និបាត។

## ជំពូកទី៣
## ការរៀបចំឯកសារសម្រាប់ចុះបញ្ជី

**ប្រការ ២២.-**

នៅក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ ក្រោយពេលមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានបញ្ចប់ គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវសម្របសម្រួលជាមួយក្រុមប្រឹក្សាភិបាលជាប់ឆ្នោតដើម្បីដាក់ពាក្យស្នើសុំការយល់ព្រមនិងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មដើម្បីទទួលបាននូវនីត្យានុកូលភាពរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

ពាក្យស្នើសុំចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវមានការបញ្ជាក់ត្រឹមត្រូវពីមេឃុំ ឬចៅសង្កាត់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមីដែលទីស្នាក់ការ ឬលេខាធិការដ្ឋានរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាតាំងនៅ។

**ប្រការ ២៣.-**

ពាក្យស្នើសុំចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវភ្ជាប់ឯកសារចាំបាច់ដូចខាងក្រោមៈ

១- របាយការណ៍មហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

២- ឯកសារស្តីពីបេសកកម្ម និងផែនការសកម្មភាពរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

៣- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

៤- បញ្ជីសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដោយបញ្ជាក់ពីអត្តសញ្ញាណ មុខរបរ និងអាសយដ្ឋាន

៥- ស្លាកសញ្ញា អាសយដ្ឋាន និងរចនាសម្ព័ន្ធរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ព្រមទាំងបញ្ជីចំនួនសមាជិកតាមបណ្តារាជធានី ខេត្ត

៦- គំរូហត្ថលេខាឬស្នាមមេដៃស្តាំរបស់ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល និងប្រធាននិង សមាជិកគណៈកម្មាធិការត្រួតពិនិត្យរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

**ប្រការ ២៤.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវទទួលពាក្យស្នើសុំចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដោយត្រូវចេញបង្កាន់ដៃទទួលដែលមានការបញ្ជាក់កាលបរិច្ឆេទទទួលពាក្យស្នើសុំច្បាស់លាស់។

អគ្គនាយកដ្ឋានកសិកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នៅក្នុងរយៈពេលមិនលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំត្រឹមត្រូវនិងគ្រប់គ្រាន់ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីសហគមន៍កសិកម្ម។

គំរូពាក្យស្នើសុំ និងគំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២៥.-**

ក្នុងករណីលទ្ធផលពិនិត្យសំណុំឯកសារពាក្យស្នើសុំចុះបញ្ជី បានរកឃើញភាពមិនសមស្រប ឬផ្ទុយទៅនឹងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីសហគមន៍កសិកម្ម នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវជូនដំណឹងចំពោះគណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដើម្បីធ្វើការកែសម្រួលឡើងវិញនូវសំណុំឯកសារពាក្យស្នើសុំចុះបញ្ជី នៅក្នុងរយៈពេលមិនលើសពី៦០(ហុកសិប)ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំចុះបញ្ជី ដើម្បីធ្វើការកែសម្រួលឡើងវិញលើចំណុចមិនសមស្រប នៅក្នុងដំណើរការបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាសាមី។

ក្នុងករណីគណៈកម្មការរៀបចំធ្វើការកែសម្រួលឡើងវិញ មិនទាន់បានត្រឹមត្រូវនៅក្នុងរយៈពេលកំណត់ក្នុងសេចក្តីជូនដំណឹង នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវសម្របសម្រួលជាមួយគណៈកម្មការរៀបចំដើម្បីកែសម្រួលនិងចុះបញ្ជី។

**ប្រការ ២៦.-**

នៅពេលដែលសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានចុះបញ្ជីទទួលស្គាល់ដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មរួច គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបញ្ចប់សុពលភាពបំពេញភារកិច្ចរបស់ខ្លួន និងត្រូវរំលាយដោយស្វ័យប្រវត្តិ។

ក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវចូលបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនចាប់ពីកាលបរិច្ឆេទដែលសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានចុះបញ្ជីជាផ្លូវការ។

សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម ត្រូវបំពេញតួនាទី ភារកិច្ច និងកាតព្វកិច្ចជាសមាជិករបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២៧.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលបានចុះបញ្ជីជាផ្លូវការដោយត្រូវបិទផ្សាយនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងជាសាធារណៈ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៩.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ.............ឆ្នាំ.... ....ស័ក ព.ស ២៥៦...

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កន្លែងទទួលៈ**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -គ្រប់រដ្ឋបាលរាជធានី ខេត្ត
- -ដូចប្រការ ២៩
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ